MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# បច្ចេកទេសចិញ្ចឹមជន្លេន និងការកែច្នៃជន្លេន

# Culturing Technique of Earthworm and Feed Processing

*(Pheretima posthuma)*



រដ្ឋបាលជលផល

មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប

ឆ្នាំ ២០១១

# បច្ចេកទេសចិញ្ចឹមជន្លេន និងការកែច្នៃជន្លេន

## Culturing Technique of Earthworm and Feed Processing


**រៀបរៀងដោយ**

លោក **ង៉ាន់ ហេង** ប្រធានមជ្ឈមណ្ឌល

លោក **សំ ណារិទ្ធ** អនុប្រធានមជ្ឈមណ្ឌល

លោក **រស់ ណារិន** មន្ត្រីបច្ចេកទេសនៃមជ្ឈមណ្ឌល

**កែសម្រួលដោយ**

ឯកឧត្តម **ណៅ ធូក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

ឯកឧត្តម **ស្រ៊ុន លឹមសុង** អនុប្រធានរដ្ឋបាលជលផល



ម.ព.ឯ.ក AIDOC

Code: 142-031

Date:

Donated by:



**ឧបត្ថម្ភបោះពុម្ពផ្សាយដោយ**

រដ្ឋបាលជលផល និង MRC

ឆ្នាំ ២០១១

# មាតិកា

អារម្ភកថា........................................................ ២
សេចក្តីផ្តើម........................................................ ៣
២. លក្ខណៈជីវសាស្ត្រ........................................................ ៣
៣. គំរូអាងសម្រាប់ចិញ្ចឹម........................................................ ៤
៣.១ រោងចិញ្ចឹមសង់ពីឥដ្ឋ........................................................ ៤
៣.២ រោងសង់ពីក្រណាត់កៅស៊ូ........................................................ ៥
៤. ពូជជន្លេន........................................................ ៥
៥. ការផ្តល់ចំណី........................................................ ៥
៦. ការងារគ្រប់គ្រង........................................................ ៦
៧. ការប្រមូលផល........................................................ ៧
៧.១ ប្រមូលផលទាំងស្រុង........................................................ ៧
៧.២ ប្រមូលផលរំលោះ........................................................ ៧
៧.៣ ការដឹកជញ្ជូន........................................................ ៧
៨. វិធីសាស្ត្រផលិតចំណីគ្រាប់........................................................ ៨
៨.១ រូបមន្តទី ១........................................................ ៨
៨.២ រូបមន្តទី ២........................................................ ៩
៩. បណ្ណាល័យសាស្ត្រ........................................................ ១១

# អារម្ភកថា

ការងារអភិវឌ្ឍន៍វារីវប្បកម្ម កាន់តែរីកចំរើនឈានឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសតំបន់ដែលនៅឆ្ងាយពីដែននេសាទ។ សកម្មភាពនៃការចិញ្ចឹម មានទាំងការចិញ្ចឹមទ្រង់ទ្រាយតូចដែលមានផ្ទៃក្រឡាស្រះចិញ្ចឹមពី ៦ ម៉ែត្រការ៉េឡើង និងឈានទៅការចិញ្ចឹមបែបពាណិជ្ជកម្ម។ ប្រជាកសិករបានចិញ្ចឹមត្រី ទាំងប្រភេទត្រីដែលស៊ីចំណីធម្មជាតិ(ប្លង់តុង) ត្រីស៊ីចម្រុះ និងប្រភេទត្រីស៊ីសាច់ជាអាហារ ដូចជាត្រីអណ្តែង ត្រីឆ្តោរ ។ល។ ជាទូទៅ អ្នកចិញ្ចឹមនៅមូលដ្ឋានមិនសូវប្រើចំណីគ្រាប់ដែលបាននាំចូលពីក្រៅប្រទេសទេ ព្រោះវាមានតម្លៃខ្ពស់ធ្វើឱ្យការចិញ្ចឹមមិនសូវចំណេញ ឬអាចខាតក៏មាន។ ឯការប្រើប្រាស់វត្ថុធាតុដើមដែលមាននៅមូលដ្ឋាន មិនអាចផ្គត់ផ្គង់បានគ្រប់គ្រាន់តាមតម្រូវការទេ ដូចជាកាកសំណល់ផ្សេងៗ កណ្ដៀរ ជន្លេនដែលជីកតាមវាលស្រែ ។ល។ កង្វះខាតខាងលើធ្វើឱ្យត្រីមានកម្រិតលូតលាស់យឺត ដោយខ្វះប្រភពប្រូតេអ៊ីនសម្រាប់ផ្សំចំណីសត្វ។

ជាទូទៅ ប្រភពប្រូតេអ៊ីនសម្រាប់ផ្សំចំណីបានមកពីម្សៅត្រី ម្សៅសណ្តែកសៀង ត្រីកាកសំណល់ កាកសំណល់សត្តឃាត ។ល។ ដើម្បីបង្កភាពងាយស្រួលដល់កសិករក្នុងការផលិតចំណីសត្វ យើងពិនិត្យឃើញថា ការចិញ្ចឹមជន្លេនជាវិធីមួយអាចជួយផ្តល់បន្ថែមនូវវត្ថុធាតុដើមក្នុងការផ្សំចំណីប្រកបដោយគុណភាពខ្ពស់។

មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប សូមចូលរួមផ្តល់នូវបទពិសោធន៍ខ្លះៗ ស្តីពីបច្ចេកទេសចិញ្ចឹមជន្លេន មានលក្ខណៈសាមញ្ញដែលប្រជាជនទូទៅអាចយកទៅអនុវត្តបាន និងការកែច្នៃជន្លេនធ្វើជាចំណីគ្រាប់ ដោយប្រើជន្លេនជំនួសម្សៅត្រី។

មជ្ឈមណ្ឌល សូមស្វាគមន៍ចំពោះរាល់ការកែលំអនូវរាល់ចំណុចខ្វះខាត ដើម្បីបង្កើនគុណភាពការយល់ដឹងសម្រាប់ជាផលប្រយោជន៍ទូទៅក្នុងកិច្ចការអភិវឌ្ឍន៍វិស័យវារីវប្បកម្មនៅកម្ពុជា។

## ១. សេចក្តីផ្តើម

ជន្លេនជាប្រភេទសត្វគ្មានឆ្អឹងកង រស់នៅ និងធ្វើការបន្តពូជក្នុងដី។ លទ្ធភាពបន្តពូជរបស់វា អាស្រ័យទៅតាមលក្ខខណ្ឌនៃបរិស្ថានមានលក្ខណៈសមស្រប និងជាពិសេសដីមានជីជាតិល្អ ព្រោះចំណីអាហាររបស់វាគឺសារធាតុសរីរាង្គនៅក្នុងដីនៅកន្លែងដែលវារស់នៅ និងកាកសំណល់ផ្សេងៗនៅទីនោះ។ នៅក្នុងធម្មជាតិ ដីកាន់តែថយជីជាតិ និងរិចរិលពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើឱ្យបរិមាណជន្លេននៅក្នុងដីក៏កាន់តែថយចុះដែរ។ វាធ្វើឱ្យដីធូរមានជីជាតិល្អ ដែលជាទូទៅគេបានដាក់ឈ្មោះឱ្យវាថា "អ្នកភ្ជួររាស់ដីធម្មជាតិ និងជាមិត្តសម្លាញ់ដ៏ជិតស្និទ្ធជាមួយកសិករ"។ ដើម្បីបង្កើនបរិមាណជន្លេនឱ្យបានច្រើនតាមតម្រូវការ សម្រាប់ផ្គត់ផ្គង់ជាចំណីសត្វ គឺមានតែការចិញ្ចឹមទេ ទើបអាចបំពេញតម្រូវការផ្គត់ផ្គង់បាន។

បច្ចេកទេសចិញ្ចឹមជន្លេនមានលក្ខណៈសាមញ្ញមិនស្មុគ្រស្មាញឡើយ តែវាក៏អាស្រ័យទៅលើលទ្ធភាពនៃការរៀបចំទីកន្លែងសម្រាប់ចិញ្ចឹមដូចជា ចំនួនអាង ពូជ និងការផ្តល់ចំណីដល់វាដែរ។ អាងសម្រាប់ចិញ្ចឹម អាចសង់បានច្រើនប្រភេទខុសៗគ្នា តែវាមិនប៉ះពាល់ដល់លទ្ធផលនៃការចិញ្ចឹមឡើយ។ ធ្វើយ៉ាងណារោងសម្រាប់ចិញ្ចឹម ត្រូវសង់ឱ្យមានភាពងងឹតច្រើនជាងពន្លឺ ព្រោះជន្លេនវាធ្វើសកម្មភាពខ្លាំង និងស៊ីចំណីនៅពេលយប់ងងឹត។

## ២. លក្ខណៈជីវសាស្ត្រ

ជន្លេនជាប្រភេទសត្វរស់នៅក្នុងដី ជម្រៅពី ៥-៧.៥ សង្ទីម៉ែត្រ មានដងខ្លួនទន់ងាយនឹងបត់បែន។ វាចេញពីរន្ធរបស់វានៅពេលយប់ដើម្បីស្វែងរកចំណីតែវាចូលទៅក្នុងរន្ធវិញនៅពេលថ្ងៃរះ។ ចំណីរបស់វាគឺសារធាតុសរីរាង្គនៅក្នុងដីដែលនៅជុំវិញរន្ធរបស់វា និងកាកសំណល់ផ្សេងៗទៀត។ នៅពេលមានភ្លៀងទឹកលិចរន្ធរបស់វាៗចេញក្រៅទៅទីទួល ដើម្បីលាក់ខ្លួននៅក្នុងគំនរសម្រាមផ្សេងៗ។ វាស៊ីសារធាតុសរីរាង្គក្នុងដីជាចំណីអាហារចូលតាមផ្លូវរំលាយអាហារ ហើយបញ្ចេញកាកសំណល់ទៅក្រៅ ដែលមានរាងជាគ្រាប់ៗគរនៅលើមាត់រន្ធរស់នៅរបស់វា។



*សរីរាង្គរបស់ជន្លេន*

ជន្លេនមានប្រវែងបណ្តោយជាមធ្យមពី ៧-១៩ សង្ទីម៉ែត្រ ជាទូទៅវាមានពណ៌សុកូឡា ឬពណ៌ត្នោត។ ផ្នែកខាងលើនៃខ្នងរបស់វាមានឆ្នូតពណ៌ខ្មៅលាតសន្ធឹងពីក្បាលដល់កន្ទុយរបស់វា។